តើអ្នកចង់បាន
បទពិសោធន៍ការងារ
ដែលមានតំលៃដែរឬទេ ?

តើអ្នកត្រូវការធ្វើចំណេះចេះដឹង
របស់អ្នកក្នុងពេលបច្ចុប្បន្ននេះអោយ
បានគ្រាន់បើជាងមុនឬទេ ?

តើអ្នកចូលចិត្តបង្កើតអោយមានទំនាក់ទំនង
បណ្តាញការងារដែរឬទេ ?

# យើងមានសេចក្តីរីករាយនឹងចង់ផ្តល់ចំលើយដល់អ្នក...

# កម្មវិធីចូលរួមក្នុងសហគមន

**The Community Participation Program**

Cambodian 2005

## ជួយយើងឲ្យអាចជួយអ្នករកវិធីរកការងារធ្វើ។

“កម្មវិធីចូលរួមក្នុងសហគមន៍បានទទួលជោគជ័យសំរាប់មន្ទីររបស់យើង ហើយអ្នកចូលរួមក៏បានទទួលជោគជ័យផងដែរ។ អ្នកចូលរួមទាំងអស់ ដែលធ្វើការជាមួយនឹងយើងបានកើនចំណេះដឹងគ្រប់ប្រភេទដែលមាន សារៈសំខាន់ចាំបាច់ដើម្បីជួយនាងឲ្យអាចរកការងារធ្វើពេញម៉ោងបាន។ តាមពិតនាងមានការណាត់ជួបដើម្បីសម្ភាសន៍ជាមួយនឹងការិយាល័យ ខេត្តរបស់អង្គការរបស់យើង។ ប្រធានសាខារបស់យើងនិងរូបខ្ញុំផ្ទាល់ នឹងជួយធ្វើជាំ (reference) អ្នកស្គាល់ពីប្រវត្តការងាររបស់នាងក្នុងពេល ដែលនាងដើររកការងារធ្វើ។”

Trish Robichaud
Director of IFS
York North Chapter of the
MS Society of Canada

“កម្មវិធី Ontario Works មានប្រយោជន៍សំរាប់កន្លែងផ្តល់ពត៌មាន Information Markham។
លោកអ្នកទាំងអស់ដែលចូលរួមនិងលោកអ្នក
ដែលមានទំនាក់ទំនងជាមួយនឹងយើងនោះមានសេចក្តីអបអរសាទរ ហើយតស៊ូយ៉ាងមោះមុតបំផុត។ វាធ្វើឲ្យយើងមានសេចក្តីរីករាយជាពន់ពេកណាស់ក្នុងការជួយជំរុញលើកទឹកចិត្តឲ្យអាចវិលត្រឡប់ទៅចូលប្រលូកក្នុងពលកម្មការងារវិញបាន។”

Leslie Walker
Executive Director
Information Markham


**Community Services and Housing Department**
Social Assistance Division
Ontario Works Program
17250 Yonge Street, Box 147
Newmarket, Ontario L3Y 6Z1

“For more information
សូមទូរស័ព្ទមកយើងលេខ 1-800-662-6640
ឬ លេខក្នុងតំបន់ (905) 895-0418
ឬ ទូរសារ៍ (905) 895-5045”

www.york.ca




# សំរាប់អនាគតដ៏ភ្លឺស្វាង

...ទាំងអស់គ្នាយើងនឹងអាចធ្វើទៅកើត

មនុស្សគ្រប់រូបបានទទួលផល
ប្រយោជន៍ពេលលោកអ្នកចូល
រួមធ្វើការស្មគ្រចិត្ត



ការហ្វឹកហាត់នៅកន្លែងធ្វើការផ្ទាល់ហើយនិងបណ្តាញការងារ




មានផ្តល់ជំនួយរកការងារធ្វើ



មានផ្តល់លុយកាក់សំរាបបង់ថ្លៃមើលថែទាំកូនក្មេង

York Region

## តើកម្មវិធីចូលរួមក្នុងសហគមន៍គឺជាអ្វី ?

កម្មវិធីចូលរួមក្នុងសហគមន៍ជាផ្នែកមួយនៃកម្មវិធីការងារ Ontario Works ហើយអ្នកដែលចូលរួមក្នុងកម្មវិធី Ontario Works នេះនឹងមានឱកាសបង្កើតជាបណ្តាញការងារយ៉ាងសំខាន់ចាំបាច់និងទទួលបាននូវបទពិសោធន៍ការងារដ៏មានតំលៃនិងមានចំណេះដឹងដែលទាក់ទងទៅនឹងការងារ។

ចំពោះលោកអ្នកដែលជាអ្នកចូលរួមក្នុងកម្មវិធី Ontario Works លោកអ្នកនឹងអាចទទួលបាននូវប្រាក់ជំនួយជាបន្តបន្ទាប់គឺពេលដែលលោកអ្នកចូលរួមជាសមាជិកស្ម័គ្រចិត្តជាមួយនឹងអង្គការណាមួយតាមរយៈកម្មវិធីចូលរួមក្នុងសហគមន៍។ លោកអ្នកក៏នឹងអាចទទួលបាននូវប្រាក់កាសសំរាប់ការចំណាយទូទៅផងដែរ គឺ Employment Related Expenses (ERE) ដើម្បីជួយដល់ការចំណាយទៅលើថ្លៃធ្វើដំណើរ ថ្លៃហ្វឹកហាត់ ថ្លៃអ្នកមើលថែទាំកូនក្មេង ថ្លៃសម្លៀកបំពាក់ពិសេស ឬសម្ភារៈប្រើប្រាស់ផ្សេងៗ។

ការចូលរួមធ្វើការក្នុងសហគមន៍ដើម្បីហ្វឹកហាត់អាចត្រូវបានទទួលការធានាពីក្រុមហ៊ុនផ្សេងៗ ដូចជាក្លឹបបំរើសេវាកម្មនិងសាធារណៈ ឬអង្គការមិនយកកំរៃណាមួយក្នុងសហគមន៍។

## តើមានហេតុអ្វីដែលធ្វើឲ្យខ្ញុំចូលក្នុងកម្មវិធីចូលរួមក្នុងសហគមន?

ការចូលរួមធ្វើការក្នុងសហគមន៍ដើម្បីហ្វឹកហាត់គឺជាមធ្យោបាយដ៏ល្អមួយដែលជួយអ្នកឲ្យរក្សាបាននូវចំណេះដឹងនាពេលបច្ចុប្បន្ន មានអ្នកស្គាល់ដែលអាចនិយាយពីប្រវត្តការងារ មានទំនាក់ទំនងជាមួយគេពេលអ្នកដើររកការងារធ្វើ កើនចំណេះចេះដឹងនិងបទពិសោធន៍ការងារ ធ្វើខ្លួនឲ្យមានតំលៃខស់និងមានសេចក្តីទុកចិត្តលើខ្លួនឯង នៅពេលជាមួយគ្នានេះដែរអ្នកក៏បានចូលរួមចំណែកមួយផ្នែកនៅក្នុងសហគមន៍របស់អ្នក។

សូមចងចាំថា គោលបំណងរបស់កម្មវិធី Ontario Works គឺស្រួលធម្មតាបំផុត- ជួយមនុស្សគ្រប់ៗរូបឲ្យទៅជាមនុស្សដែលមានម្ចាស់ការលើខ្លួនឯងក្នុងការរកប្រាក់កាស។

## តើការនិយាយរៀបរាប់ពីសមត្ថភាពរបស់ខ្លួនឯងនោះគឺជាអ្វី ?

ការនិយាយរៀបរាប់ពីសមត្ថភាពខ្លួនឯងគឺជាមធ្យោបាយដ៏ល្អមួយដើម្បីដើររកកន្លែងធ្វើការស្ម័គ្រចិត្តដែលសមរម្យសំរាប់អ្នក។ មានកន្លែងច្រើនណាស់ដែលអ្នកអាចចាប់ផ្តើមរកកន្លែងធ្វើការស្ម័គ្រចិត្តបាន: សៀវភៅរាយឈ្មោះក្រសួងផ្សេងៗនៅក្នុងសហគមន៍ដូចជា York Link កាសែតក្នុងតំបន់ បណ្ណាល័យក្នុងតំបន់ សៀវភៅលឿង ហើយតាមពិតគឺនៅមានការិយាល័យ Ontario Works នៅក្នុងតំបន់របស់អ្នក។

បើប្រសិនជាការនិយាយរៀបរាប់អំពីសមត្ថភាពខ្លួនឯងហាក់ដូចជាបើកឱកាសឲ្យអ្នកបន្តទៅមុខទៀតបាននោះ បុគ្គលិកការិយាល័យ Ontario Works ក្នុងតំបន់របស់អ្នកអាចផ្តល់ក្រដាសក្បួនណែនាំអំពីការនិយាយរៀបរាប់ពីសមត្ថភាពខ្លួនឯង ក្រដាសណែនាំនេះប្រាប់ចំណុចសំខាន់ៗនិងពត៌មានដ៏មានតំលៃស្តីពីការនិយាយរៀបរាប់ពីសមត្ថភាពខ្លួនឯង។

## តើអ្វីទៅជាថ្នូររបស់ការស្ម័គ្រចិត្ត ?

បើប្រសិនជាអ្នកកំពុងតែធ្វើជាអ្នកស្ម័គ្រចិត្តឲ្យក្រុមណាមួយក្នុងសហគមន៍ក្លឹបសេវាកម្ម សាធារណៈ ឬ អង្គការមិនយកកំរៃ អ្នកអាចរាប់បញ្ចូលកិច្ចការទាំងអស់នេះចូលទៅក្នុង Ontario Works ការចូលរួមធ្វើការក្នុងសហគមន៍ដើម្បីហ្វឹកហាត់។

ដើម្បីប្តូរម៉ោងស្ម័គ្រចិត្តរបស់អ្នកនាពេលបច្ចុប្បន្នឲ្យទៅជាម៉ោងសំរាប់ការចូលរួមក្នុងសហគមន៍ អ្នកគ្រាន់តែសុំសំបុត្រមួយសន្លឹកពីអង្គការកន្លែងដែលអ្នកចូលស្ម័គ្រចិត្តហើយយកសំបុត្រនោះទៅឲ្យអ្នកធ្វើការផ្នែកសង្គមកិច្ច។ សំបុត្រនោះត្រូវតែមានប្រាប់ទីកន្លែងដែលអ្នកចូលធ្វើការស្ម័គ្រចិត្ត ចំនួនម៉ោងដែលអ្នកស្ម័គ្រចិត្តក្នុង១ខែៗហើយនិងប្រាប់ពីមុខងារដែលអ្នកធ្វើនៅទីនោះ។ អ្នកធ្វើការរបស់អ្នកនឹងលៃលកធ្វើយ៉ាងណាឲ្យអ្នកនៅតែបានទទួលការគាំទ្រដើម្បីបន្តការស្ម័គ្រចិត្តហើយម៉ោងស្ម័គ្រចិត្តនោះរាប់បញ្ចូលទៅក្នុងសកម្មភាព Ontario Works.

## តើមានសកម្មភាពស្ម័គ្រចិត្តអ្វីខ្លះដែលខ្ញុំអាចចូលរួមបាន?

តាមពិតសកម្មភាពនៃការចូលរួមធ្វើការក្នុងសហគមន៍គឺមានកំណត់តែនៅក្នុងចិត្តនិងការយល់ឃើញរបស់យើងប៉ុណ្ណោះទេ។ បញ្ជីខាងក្រោមនេះប្រហែលជាអាចជួយបំភ្លឺអ្នកឲ្យគិតគូរអំពីការចូលរួមដើម្បីធ្វើការហ្វឹកហាត់ណាមួយដែលសមរម្យចំពោះរូបអ្នកបា

- ទីផ្សារ (កន្លែងទិញឬលក់) កិច្ចការស្មៀន អ្នកទទួលភ្ញៀវ និងកិច្ចការការិយាល័យ
- កិច្ចការកុំព្យូទ័រដូចជារៀបចំគ្រឿងម៉ាស៊ីនកុំព្យូទ័រ បញ្ចូលទិន្នន័យ និងជួយដោះស្រាយបញ្ហាម៉ាស៊ីនកុំព្យូទ័រ
- គណនេយ្យនិងការរក្សាបញ្ជីឬរបាយការណ៍
- ធ្វើកិច្ចការលើគំរោងការពិសេស ពិធីបុណ្យពិសេស ធ្វើដំណើរទេសចរណ៍ រៃអង្គាសលុយ ស្រាវជ្រាវ
- ផ្តល់ជំនួយដល់មណ្ឌលមើលថែទាំកូនក្មេង មណ្ឌលថែទាំមនុស្សចាស់ជរា មន្ទីរពេទ្យធំ
- ធ្វើជាអ្នកជួយបង្ហាត់ ជួយនៅក្នុងសាលារៀន សារៈមន្ទីរនិងបណ្ណាល័យ
- ធ្វើការជាមួយក្រុមកីឡាផ្សេងៗផ្នែកបរិដ្ឋានឬក្រុមធ្វើសកម្មភាពលំហែរ
- ឈូសដីនិងដាំដើមឈើលំអ ការថែទាំទីកន្លែងណាមួយ

## តើលោកអ្នកចង់បានពត៌មានបន្ថែមទៀតឬទេ ?

Ontario Works មានការប្រជុំទៀងទាត់ដើម្បីផ្តល់ពត៌មានដល់លោកអ្នកឲ្យអាចចូលក្នុងកម្មវិធីចូលរួមក្នុងសហគមន៍ដើម្បីហ្វឹកហាត់។ សូមទាក់ទងអ្នកធ្វើការផ្នែកសង្គមកិច្ចដើម្បីចុះឈ្មោះនៅក្នុងថ្ងៃនេះ។

...រួបរួមគ្នាធ្វើឲ្យមនុស្សគ្រប់រូបបានសំរេចច្រើន

Ontario Works
Together, We Will Do It